# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ សាកលវិទ្យាល័យកំពង់ចាម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

-តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

# សម្រេច

**មាត្រា ១ ៖** ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យកំពង់ចាម** ( The University of Kampong Cham ) សរសេរកាត់ជាភាសាខ្មែរ " **ស.ក.ច** " និង សរសេរកាត់ជាភាសាអង់គ្លេស " **UKC** "។

**មាត្រា ២ ៖** សាកលវិទ្យាល័យកំពង់ចាម មានទីតាំងឋិតនៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម និង ឋិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ៣ ៖** សាកលវិទ្យាល័យកំពង់ចាម ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និង បរិញ្ញាបត្រ លើមហាវិទ្យាល័យបី ៖

-មហាវិទ្យាល័យវិទ្យាសាស្ត្រ

-មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

-មហាវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

ទៅអនាគត សាកលវិទ្យាល័យកំពង់ចាម ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និង មុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និង កីឡា។ សាកលវិទ្យាល័យនេះ អាចបើកសាខាមហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតថ្មី ឬ ថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬ ទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ៤ ៖** សាកលវិទ្យាល័យកំពង់ចាម ត្រូវរៀបចំក្រុមប្រឹក្សាភិបាលមួយ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និង កីឡា ដើម្បីពិនិត្យ និង សម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា ៥ ៖** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យកំពង់ចាម មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យកំពង់ចាម និង ធានាឱ្យមានសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម

-ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឱ្យចូលរៀន និង ទទួលនិស្សិតឱ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់ សាកលវិទ្យាល័យកំពង់ចាម

-អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ

-រៀបចំតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ និង បទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងការសិក្សា ឱ្យបានច្បាស់លាស់

-ធ្វើរបាយការណ៍ជូនក្រសួងអប់រំ យុវជន និង កីឡា តាមការកំណត់។

**មាត្រា ៦ ៖** និស្សិតសាកលវិទ្យាល័យកំពង់ចាម ដែលបានរៀនចប់កម្មវិធីសិក្សា និង ទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និង មុខជំនាញ ដែលបានសិក្សា។ សញ្ញាបត្រ

នេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យកំពង់ចាម ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីសាកលវិទ្យាល័យកំពង់ចាម បំពេញ និង អនុវត្តបានតាមគោលការណ៍ និង បទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ៧ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ប្រធានស្ថាប័ន ពាក់ព័ន្ធ និង ក្រុមប្រឹក្សាភិបាល រួមជាមួយ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យកំពង់ចាម ត្រូវទទួល បន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សាលាខេត្តកំពង់ចាម
-រាជកិច្ច
-ដូចមាត្រា ៧ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ